# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1022

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍សម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការលើកកម្ពស់កសិ-អាជីវកម្មនៅក្នុងប្រទេសកម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/26

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/28

៣. ចំណាយគម្រោងសរុប $3,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងអភិវឌ្ឍន៍ជនបទ

RESPONSIBLE UNIT Community Development Department ( CDD )

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

-លើកកម្ពស់ធុរៈកិច្ចកសិកម្ម និងការអភិវឌ្ឍន៍ធនធានមនុស្ស

-មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ត្រូវបានបង្កើត

-តំបន់ធ្វើកសិកម្មចម្រុះតាមបែបធម្មជាតិគ្មានជាតិគីមីត្រូវបានបង្កើត

-បច្ចេកវិទ្យាធុរៈកិច្ចកសិកម្ម និងជំនាញផ្សេងៗត្រូវបានបង្ហាត់បង្រៀនដល់កសិករកម្ពុជា

-បណ្តុះបណ្តាលមន្ត្រីសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីជំនាញភាពជាអ្នកដឹកនាំ និងជំនាញគ្រប់គ្រង ។ល។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិវឌ្ឍន៍ជនបទ

Other

Other

Other

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

តាកែវ,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

-បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍
-បង្កើតតំបន់ធ្វើកសិកម្មចម្រុះតាមបែបធម្មជាតិគ្មានជាតិគីមី
-ទទួលបាននូវចំនេះដឹង និងចំនេះធ្វើលើផ្នែកធុរៈកិច្ចកសិកម្ម
-ការទទួលបានចំនេះដឹងលើផ្នែកភាពជាអ្នកដឹកនាំ ជំនាញផ្នែកទីផ្សារ ជំនាញគ្រប់គ្រង រួមមាន គោលនយោបាយ និងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ ទស្សនៈទានអភិវឌ្ឍន៍សហគមន៍ជនបទ
-ការទទួលបានចំនេះដឹងលើផ្នែកបច្ចេកទេសកសិកម្មឆ្លាតវៃ និងជំនាញផ្សេងៗ។

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

I. សកម្មភាព១៖ ផ្នែករឹង
-បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍
-បង្កើតតំបន់ធ្វើកសិកម្មចម្រុះតាមបែបធម្មជាតិគ្មានជាតិគីមី
-បង្កើតឲ្យមានបរិក្ខាកសិកម្មឆ្លាតវៃ និងបរិក្ខាធុរៈកិច្ចកសិកម្ម
-បង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ធុរៈកិច្ចកសិកម្ម។
II.សកម្មភាព២៖ ការកសាងសមត្ថភាព
១.បង្កើតក្រុមសម្របសម្រួល និងគ្រប់គ្រងគម្រោង (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)
-ជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ
-ជំនាញសម្របសម្រួល និងទំនាក់ទំនង
-ជំនាញគ្រប់គ្រងជម្លោះ និងការដោះស្រាយបញ្ហា
-សហគ្រិនភាពសង្គម
-ការបំប្រែបំរួលអាកាសធាតុ
-ផ្សេងៗ
២.កម្រិតសហគមន៍
-ជំនាញធុរៈកិច្ចកសិកម្ម
-ជំនាញបច្ចេកវិទ្យាកសិកម្មឆ្លាតវៃ
-ជំនាញភាពជាអ្នកដឹកនាំ និងការងារគ្រប់គ្រង
-ជំនាញទីផ្សារ
-ជំនាញសហគ្រិនភាពសង្គម
-ការបំប្រែបំរួលអាកាសធាតុ
-ផ្សេងៗ
III.សកម្មភាព៣៖ ការគាំទ្រធុរៈកិច្ចកសិកម្ម
-ផ្តល់នូវសម្ភារៈ សម្រាប់ការធ្វើធុរៈកិច្ចកសិកម្មដល់កសិករ
IV.សកម្មភាព៤៖ បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ
V.សកម្មភាព៥៖ បង្កើតប្រព័ន្ធការពារ និងនិរន្តរភាពគម្រោង។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

KRC នៃសាធារណរដ្ឋកូរ៉េ
និងរដ្ឋាភិបាលកម្ពុជាបានមានទំនាក់ទំនងកិច្ចសហប្រតិបត្តិការយ៉ាងល្អជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកលើផ្នែកអភិវឌ្ឍន៍
និងផ្នែកបណ្តុះបណ្តាលកសាងសមត្ថភាពដល់មន្រ្តីរាជការកម្ពុជា។
រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េមានភាពជោគជ័យយ៉ាងខ្លាំងអំពីការកសាងសមត្ថភាពសម្រាប់ជនជាតិកូរ៉េ
ដើម្បីធ្វើឲ្យមានការអភិវឌ្ឍន៍ប្រទេសប្រកបដោយចិរភាព និងបានប្រែក្លាយទៅជាប្រទេសអភិវឌ្ឍន៍រហូតមកដល់ពេលបច្ចុប្បន្ន។ ដូច្នេះ
យើងមានការជឿជាក់យ៉ាងម៉ុតមាំដើម្បីរៀបចំអនុវត្តគម្រោង ការកសាងសមត្ថភាព និងការគាំទ្រធុរៈកិច្ចកសិកម្ម។
យើងមានបំណងរៀនសូត្រអំពីគំរូនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ពីមិត្តកូរ៉េជាពិសេសធ្វើយ៉ាងណាដើម្បីបង្កើតគោលនយោបាយអនុវត្តគម
្រោងនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

១.ដោយផ្ទាល់៖
-មន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទនឹងទទួលបានផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងលើការកសាងសមត្ថភាព
-ប្រជាពលរដ្ឋក្នុងភូមិគោលដៅ នឹងទទួលបានផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងលើការកសាងសមត្ថភាព បច្ចេកទេស
និងការគាំទ្រហិរញ្ញវត្ថុ។
២.ដោយប្រយោល៖
-ភូមិទាំងឡាយដែលនៅជាប់ឬក្បែរភូមិអនុវត្តគម្រោង នឹងទទួលបានប្រយោជន៍ពីផលប៉ះពាល់ជាវិជ្ជមានពីគម្រោង។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គ្មានទេ**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៨. ជីវភាពរស់នៅ (ទូទៅ)** | 1 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**-គម្រោងនេះនឹងជម្រុញឲ្យមានការចូលរួមពីស្ត្រីយ៉ាងហោចណាស់ ៣០%**
**-គោលបំណង និងគោលដៅនៃគម្រោងនេះ នឹងធ្វើឲ្យមានវិសមភាពGender និងការផ្តល់សិទ្ធអំណាចដល់ស្ត្រីដោយផ្តល់ឱកាសឲ្យពួកគាត់ទទួលបាននូវចំណេះដឹងផ្នែកសហគមន៍ជាពិសេស យុទ្ធសាស្ត្រអភិវឌ្ឍន៍ បច្ចេកទេស និងការរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ។ គម្រោងនេះនឹងធានាថា ទាំងបុរស ទាំងស្ត្រី នឹងទទួលបានផលប្រយោជន៍ដូចគ្នាជាពិសេសលើផ្នែកចំនេះដឹង។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នៃក្រសួងអភិវឌ្ឍន៍ជនបទ នឹងទទួលបន្ទុកអនុវត្តគម្រោងនេះ។
*ក្រសួងអភិវឌ្ឍន៍ជនបទ៖
-បង្កើតរចនាសម្ព័ន្ធសម្របសម្រួល និងគ្រប់គ្រងគម្រោង ដើម្បីគាំទ្រដំណើរការអនុវត្តគម្រោងទាំងមូល
-បង្កើតផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលគម្រោង។
*ក្រុមសម្របសម្រួលគម្រោង៖
-សម្របសម្រួលការអនុវត្តគម្រោងទូទៅ ដូចជាការចងក្រងរើសភូមិគោលដៅ និងការអនុវត្តគម្រោងនៅក្នុងភូមិគោលដៅនីមួយៗ។
*មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍៖
-ផ្តល់វគ្គបណ្តុះបណ្តាលការកសាងសមត្ថភាព ជំនាញកសិកម្ម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
-ជួយគាំទ្រការពង្រីកការអភិវឌ្ឍដល់ភូមិគោលដៅនីមួយៗ។ល។
*មន្ទីរអភិវឌ្ឍន៍ជនបទខេត្តគោលដៅ៖
-ជួយសម្រួលដល់នីតិវិធីអនុវត្តគម្រោងជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនានា
-អនុវត្តពិនិត្យតាមដាន និងធ្វើរបាយការណ៍មកក្រសួងអភិវឌ្ឍន៍ជនបទ។

គ្មានទេ

២៤. **អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

២៥. **ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

* KRC នៃសាធារណរដ្ឋកូរ៉េ៖
-ផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់ការអនុវត្តគម្រោង
-ការផ្តល់ការវាយតម្លៃ និងជួយគាំទ្រសម្រាប់សកម្មភាពតាមដានការអនុវត្តគម្រោង
-ផ្តល់អ្នកជំនាញសម្រាប់កិច្ចការប្រឹក្សាយោបល់ផ្សេងៗ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 2,000.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.0 | 0.0 | 2,000.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 2,000.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 2,000.0 | 1,000.0 | 1,000.0 | 1,000.0 | 3,000.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: